**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

ស្តីពីការបន្តព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និងក្រុមហ៊ុន ម៉េម៉ែរអង្គរ (ខេមបូឌា) កាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន ក្រុមហ៊ុន ម៉េម៉ែអង្គរ (ខេមបូឌា) មានអាសយដ្ឋានស្ថិតនៅ ភូមិវិហារចិន សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប។

## សមាសភាពចូលរួមក្នុងអង្គប្រជុំមាន៖

| | | |
|---|---|---|
| **ក. តំណាងភាគីនិយោជក** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
| លោក សែត កៅ | អគ្គនាយក | ០៦៩ ៤៨៩ ៩៩៩ |
| អ្នកស្រី អ៊ុក សោភ័ណនារី | ប្រធានផ្នែកធនធានមនុស្ស | ០៦៩ ២៣៧ ៨៨៨ |
| **ខ. តំណាងភាគីកម្មករនិយោជិត** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
| លោក គង់ ចាន់ថន | ប្រតិភូបុគ្គលិកពេញសិទ្ធិ | ០៦៩ ២៣៩ ៧៧៧ |
| លោក ហេង សេងហ៊ាន់ | ប្រតិភូបុគ្គលិកជំនួយ | ០១២ ៩៩៤ ៦៦០ |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធទៅនឹង ការព្យួរកិច្ចសន្យាការងារឲ្យបានសមស្របតាម សេចក្តីណែនាំលេខ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីទាំងពីរបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតចំនួន១៥៦នាក់ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ដោយទទួលបាននូវប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ៤០ដុល្លាអាមេ-រិក ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមទៅដល់កម្មករនិយោជិតក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺ COVID-19 ធ្វើឲ្យបាត់បង់ប្រាក់ចំណូលហើយបង្ខំចិត្តផ្អាកអាជីវកម្មមួយរយៈ។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១៦ និង ៣០នាទី រសៀល ថ្ងៃ ខែ ឆ្នាំដដែល ដោយមានការចុះហត្ថលេខា ព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម៖

**តំណាងភាគីនិយោជក**

ហត្ថលេខា/ស្នាមមេដៃ

លោក សែត កៅ

អគ្គនាយក

អ្នកស្រី អ៊ុក សោភ័ណនារី

ប្រធានផ្នែកធនធានមនុស្ស

**តំណាងភាគីកម្មករនិយោជិត**

ហត្ថលេខា/ស្នាមមេដៃ

លោក គង់ ចាន់ថន

ប្រតិភូបុគ្គលិកពេញសិទ្ធិ

លោក ហេង សេងហ៊ាន់

ប្រតិភូបុគ្គលិកជំនួយ